មន្ត្រីនៃរដ្ឋមាសាឈូសេត **Massachusetts**

ទម្រង់បែបបទសម្រាប់អ្នកបោះឆ្នោតតាមការធ្វើតាមប៉ុស្តិ៍ប្រៃសណីយ៍

របៀបប្រើប្រាស់ទម្រង់បែបបទនេះ

1. បញ្ជាក់អំពីសញ្ជាតិលោកអ្នក។
2. ចូរសរសេរឈ្មោះរបស់លោកអ្នកជាអក្សរពុម្ពធំ ៖ នាមត្រកូល នាមខ្លួន នាមកណ្តាល ឬនាមអក្សរដើមទីមួយ
3. ចូរសរសេរឈ្មោះពីមុនរបស់លោកអ្នកជាអក្សរពុម្ពធំ ប្រសិនបើមាន។
4. ចូរសរសេរអាសយដ្ឋានដែលលោកអ្នករស់នៅបច្ចុប្បន្នជាអក្សរពុម្ពធំ ៖ ឈ្មោះ និងលេខផ្លូវ ឬលេខផ្លូវជនបទ និងលេខប្រអប់សំបុត្រ (មិនត្រូវផ្តល់លេខប្រអប់សំបុត្រប្រៃសណីយ៍នោះទេ) លេខអាជ្ញាធរមេទ្ធរមគារ ទីក្រុង ឬទីប្រជុំជន និងលេខកូដតំបន់ពេញលេញ។ ចូរប្រើប្រាស់ផែនទី† នៅខាងស្តាំ ប្រសិនបើលោកអ្នកមិនអាចកំណត់អាសយដ្ឋានរបស់លោកអ្នកបានទេនោះ។
5. ចូរសរសេរអាសយដ្ឋានដែលលោកអ្នកទទួលសំបុត្រតាមប្រៃសណីយ៍របស់លោកអ្នកទាំងអស់ ប្រសិនបើអាសយដ្ឋាននោះខុសពីអាសយដ្ឋានដែលបានបញ្ចូលក្នុង #4។
6. ចូរសរសេរថ្ងៃខែឆ្នាំកំណើតរបស់លោកអ្នកជាអក្សរពុម្ពធំ ៖ ខែ ថ្ងៃ និងឆ្នាំ។ ប្រសិនបើលោកអ្នកមានអាយុ 16 ឬ 17 ឆ្នាំ លោកអ្នកនឹងត្រូវបានគេចុះបញ្ជីឈ្មោះជាមុន រហូតដល់លោកអ្នកមានអាយុគ្រប់ ដើម្បីបោះឆ្នោត។ លោកអ្នកនឹងត្រូវបានគេជូនដំណឹងតាមសំបុត្រតាមប៉ុស្តិ៍ប្រៃសណីយ៍ នៅពេលលោកអ្នកមានសិទ្ធិស្របច្បាប់ដើម្បីបោះឆ្នោត។
7. ច្បាប់សហព័ន្ធទាមទារឲ្យលោកអ្នកផ្តល់លេខប័ណ្ណបើកបររបស់លោកអ្នកដើម្បីចុះបញ្ជីឈ្មោះបោះឆ្នោត។ ប្រសិនបើលោកអ្នកមិនមានប័ណ្ណបើកបរដែលមានសុពលភាព និងថ្មីរបស់រដ្ឋម៉ាសាឈូសេត លោកអ្នកត្រូវផ្តល់លេខបួនខ្ទង់ចុងក្រោយនៃលេខប័ណ្ណសន្តិសុខសង្គមរបស់លោក។ ប្រសិនបើលោកអ្នកមិនមានប័ណ្ណទាំងពីរនេះទេ លោកអ្នកត្រូវសរសេរថា "none" នៅក្នុងប្រអប់។
8. ការផ្តល់លេខទូរស័ព្ទរបស់លោកអ្នក គឺជាជម្រើសរបស់លោកអ្នក។ ប្រសិនបើលោកអ្នកសរសេរចូលលេខទូរស័ព្ទរបស់លោកអ្នក ហើយលោកអ្នកមិនបានគូសបើពាក្យថា "មិនចុះបញ្ជីឈ្មោះ" នោះលេខទូរស័ព្ទរបស់លោកអ្នកនឹងត្រូវបានកត់ត្រាជាសាធារណៈ។
9. គូសយកគណបក្សមួយ 'គ្មានគណបក្ស' ឬ សរសេរជាអក្សរពុម្ពរចនាសម្ព័ន្ធនយោបាយ (មិនមែនគណបក្ស)។
10. សរសេរអាសយដ្ឋានដែលជាទីកន្លែងលោកអ្នកបានចុះឈ្មោះបោះឆ្នោតចុងក្រោយជាអក្សរពុម្ពធំ។
11. ប្រសិនបើមនុស្សម្នាក់កំពុងជួយលោកអ្នកដោយសារលោកអ្នកមិនអាចចុះហត្ថលេខាលើទម្រង់បែបបទនេះដោយផ្ទាល់ បុគ្គលនោះត្រូវកត់សរសេរឈ្មោះរបស់ខ្លួន និងអាសយដ្ឋានជាអក្សរពុម្ពធំ ហើយបុគ្គលនោះមានជម្រើសក្នុងការសរសេរលេខទូរស័ព្ទរបស់ខ្លួនជាអក្សរពុម្ពធំ។
12. ចូរអានសម្បថ។
13. ចូរសរសេរកាលបរិច្ឆេទនៅថ្ងៃនេះ។
14. ចុះហត្ថលេខាឈ្មោះរបស់លោកអ្នក។

ទម្រង់បែបបទនេះ អាចត្រូវបានបញ្ជូនតាមប៉ុស្តិ៍ប្រៃសណីយ៍ ឬត្រូវផ្តល់ជូនដោយផ្ទាល់ដៃទៅសាលាក្រុង ឬសាលាខេត្តរបស់លោកអ្នក។ ប្រសិនបើបានធ្វើសំបុត្រតាមប៉ុស្តិ៍ប្រៃសណីយ៍ ចូរបត់ទម្រង់បែបបទនេះ បិទឲ្យជិត បោះត្រាថ្នាក់ទីមួយ សរសេរជាអក្សរពុម្ពធំនៃឈ្មោះទីក្រុង ឬទីប្រជុំជនដែលលោកអ្នករស់នៅ និងលេខកូដស៊ីបរបស់សាលាក្រុងនោះ និងដាក់ចូលទៅប្រអប់សំបុត្រប៉ុស្តិ៍ប្រៃសណីយ៍ណាមួយ។

William Francis Galvin
លេខាធិការសហគមន៍

លោកអ្នកអាចប្រើប្រាស់ទម្រង់បែបបទនេះ ដើម្បី ៖

- ចុះឈ្មោះ ឬចុះឈ្មោះជាមុន ដើម្បីបោះឆ្នោតនៅក្នុងរដ្ឋម៉ាសាឈូសេត និង/ឬ
- ធ្វើបច្ចុប្បន្នភាពឈ្មោះ ឬអាសយដ្ឋាន និងគណបក្សនយោបាយរបស់លោកអ្នក។

ដើម្បីចុះឈ្មោះ ឬចុះឈ្មោះជាមុន ដើម្បីបោះឆ្នោតនៅក្នុងរដ្ឋម៉ាសាឈូសេត លោកអ្នក ៖

- **ជាពលរដ្ឋអាមេរិក** និង
- ជាពលរដ្ឋរស់នៅក្នុងរដ្ឋម៉ាសាឈូសេត និង
- មានអាយុយ៉ាងតិច 16 ឆ្នាំ។

ការដាក់ទោសទណ្ឌ ឬពិន័យចំពោះការចុះឈ្មោះខុសច្បាប់ ៖ ពិន័យមិនលើសពី 10,000 ដុល្លារ ឬដាក់គុកមិនលើសពីប្រាំឆ្នាំ ឬក៏ពិន័យផងនិងជាប់គុកផង។
-ច្បាប់ទូទៅរបស់រដ្ឋម៉ាសាឈូសេត ជំពូក 56 ផ្នែក 8។

ការកំណត់អត្តសញ្ញាណដែលត្រូវផ្តល់ជូន

ផ្នែក 7 ទាមទារឲ្យលោកអ្នកសរសេរបញ្ចូលលេខប័ណ្ណបើកបររបស់លោកអ្នក ឬលេខ 4 ខ្ទង់ចុងរបស់ប័ណ្ណសន្តិសុខសង្គមនៅលើទម្រង់បែបបទនេះ។ ព័ត៌មាននេះ នឹងត្រូវបានផ្ទៀងផ្ទាត់តាមរយៈការិយាល័យចុះបញ្ជីឈ្មោះយានយន្ត និងស្នងការសន្តិសុខសង្គម។ ប្រសិនបើព័ត៌មិនអាចផ្ទៀងផ្ទាត់ ឬលោកអ្នកមិនផ្តល់ព័ត៌មាននេះ លោកអ្នកត្រូវតែផ្តល់ការកំណត់អត្តសញ្ញាណទាំងនៅក្នុងទម្រង់បែបបទនេះ ឬនៅទីតាំងដែលលោកអ្នកទៅបោះឆ្នោត។ ការកំណត់អត្តសញ្ញាណគ្រប់គ្រាន់រួមមាន លិខិតថតចម្លងអត្តសញ្ញាណប័ណ្ណបច្ចុប្បន្ន និងរូបថតថ្មី វិក្កយបត្រប្រើប្រាស់សេវាសាធារណៈបច្ចុប្បន្ន រាយការណ៍ធនាគារ មូលប្បទានបត្ររដ្ឋាភិបាល ឯកសារប្រាក់ឈៀវត្សរ៍ ឬឯកសាររដ្ឋាភិបាលផ្សេងទៀត ដែលបង្ហាញឈ្មោះ និងអាសយដ្ឋានរបស់លោកអ្នក។



†ប្រើប្រាស់ចំណុចគោល គួរពីទីតាំងនៃទីកន្លែងដែលលោកអ្នករស់នៅ ប្រសិនបើលោកអ្នកមិនអាចរៀបរាប់ទីកន្លែងនោះចេញជាលេខទីតាំង ឈ្មោះផ្លូវ ឬផ្លូវជនបទ និងលេខប្រអប់សំបុត្រនោះទេ។

សរសេរព័ត៌មានទាំងអស់ជាអក្សរពុម្ពធំ ដោយប្រើប៊ិចពណ៌ខ្មៅ។ ធ្វើតាមការណែនាំខាងលើ សម្រាប់ការធ្វើទម្រង់បែបបទត្រឹមត្រូវ។

1 **គូសយកមួយ ៖** តើលោកអ្នកជាពលរដ្ឋអាមេរិកមែនទេ ? ☐ បាទ/ចាស់ ☐ ទេ កំណត់សម្គាល់ ៖ ប្រសិនបើលោកអ្នកបានគូសយក "ទេ" សូមកុំបំពេញទម្រង់បែបបទនេះ។

2 **ឈ្មោះពេញលេញ ៖** *នាមត្រកូល* *នាមខ្លួន* *នាមកណ្តាល ឬនាមអក្សរដើមទីមួយ* ☐ *Jr.* ☐ *Sr.* ☐ *II* ☐ *III* ☐ *IV* *(ចូរគូរវង្វង់មួយ បើសមរម្យ)*
☐ *កញ្ញា* ☐ *កញ្ញា ឬអ្នកស្រី* ☐ *អ្នកស្រី* ☐ *លោក*

3 **ឈ្មោះពីមុន ៖** *នាមត្រកូល* *នាមខ្លួន* *នាមកណ្តាល ឬនាមអក្សរដើមទីមួយ* ☐ *Jr.* ☐ *Sr.* ☐ *II* ☐ *III* ☐ *IV* *(ចូរគូរវង្វង់មួយ បើសមរម្យ)*
☐ *កញ្ញា* ☐ *កញ្ញា ឬអ្នកស្រី* ☐ *អ្នកស្រី* ☐ *លោក*

4 **អាសយដ្ឋានដែលលោកអ្នករស់នៅបច្ចុប្បន្ន** *(លេខផ្លូវ /ឈ្មោះផ្លូវ /លេខផ្លូវជនបទ និងលេខប្រអប់សំបុត្រ លេខអាជ្ញាធរមិនមេ្ធរមគារ / ទីក្រុង ឬខេត្ត / លេខកូដស៊ីប) ៖*

5 **អាសយដ្ឋានដែលលោកអ្នកទទួលបានសំបុត្ររបស់លោកអ្នកទាំងអស់** (ប្រសិនបើខុសពីលេខ #4) ៖

6 **ថ្ងៃខែឆ្នាំកំណើត ៖** *ខែ ថ្ងៃ និងឆ្នាំ*

7 **លេខអត្តសញ្ញាណ # ៖** *លេខប័ណ្ណបើកបរ # ឬលេខបួនខ្ទង់ចុងក្រោយនៃប័ណ្ណសន្តិសុខសង្គម(SSN)។*

8 **ទូរស័ព្ទ** (ដែលមានជម្រើស)៖ ☐ ចូរគូសយកបើមិនបានបញ្ចូលបញ្ជីឈ្មោះ

9 **ការចុះឈ្មោះគណបក្សឬរចនាសម្ព័ន្ធគណបក្ស** (គូសយកមួយ) ៖ ☐ *គណបក្សប្រជាធិបតេយ្យ* ☐ *គណបក្សសាធារណរដ្ឋ* ☐ *គណបក្សគ្រីនរ៉ានបូ (Green-Rainbow)*
☐ *គណបក្សឯករាជ្យរួមគ្នា* ☐ *គ្មានគណបក្ស (មិនចុះឈ្មោះ)* ☐ *រចនាសម្ព័ន្ធនយោបាយ (គ្មានគណបក្សនយោបាយ) ៖*

10 **អាសយដ្ឋានដែលជាទីកន្លែងលោកអ្នកបានចុះឈ្មោះបោះឆ្នោតចុងក្រោយ** *(លេខផ្លូវ /ឈ្មោះផ្លូវ /លេខផ្លូវជនបទ និងលេខប្រអប់សំបុត្រ លេខអាជ្ញាធរមិនមេ្ធរមគារ / ទីក្រុង ឬខេត្ត / លេខកូដស៊ីប) ៖*

11 ប្រសិនបើបេក្ខជន មិនអាចចុះហត្ថលេខាលើទម្រង់បែបបទនេះទេ ចូរផ្តល់ឈ្មោះ អាសយដ្ឋាន និងលេខទូរស័ព្ទ (ដែលមានជម្រើស) របស់បុគ្គលដែលជួយបេក្ខជន ៖
ឈ្មោះ *អាសយដ្ឋាន* *លេខទូរស័ព្ទ (ដែលមានជម្រើស)*

12 **ហេតុផ្លូវច្នេះ ខ្ញុំសូមស្បថ (អ:អាង)** ថា ខ្ញុំគឺជាបុគ្គលដែលមានឈ្មោះដូចខាងលើ ហើយព័ត៌មានខាងលើគឺពិតប្រាកដ **ខ្ញុំសូមស្បថថា ខ្ញុំគឺជាពលរដ្ឋអាមេរិក**, ខ្ញុំមានអាយុយ៉ាងតិច 16 ឆ្នាំ ហើយខ្ញុំយល់ថាខ្ញុំត្រូវមានអាយុ 18 ឆ្នាំ ដើម្បីមានសិទ្ធិស្របច្បាប់បោះឆ្នោត, ខ្ញុំមិនមែនជាបុគ្គលដែលស្ថិតនៅក្រោមភាពជាអាណាព្យាបាល ដែលបហាមឃាត់មិនឲ្យខ្ញុំចុះឈ្មោះបោះឆ្នោតនោះទេ, ខ្ញុំសូមអះអាងថា ខ្ញុំមិនមែនជាបុគ្គលដែលត្រូវបានបហាមឃាត់ដោយច្បាប់ជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍មិនឲ្យចូលរួមក្នុងការបោះឆ្នោតដោយសារតែអំពើពុករលួយនៅក្នុងការបោះឆ្នោតនោះទេ, បច្ចុប្បន្ន ខ្ញុំក៏មិនត្រូវបានជាប់គុកពីបទឧក្រិដ្ឋកម្មធ្ងន់ធ្ងរណាមួយឡើយ, ខ្ញុំចាត់ទុកថាលំនៅដ្ឋានេះគឺជាផ្ទះរបស់ខ្ញុំ។ បានចុះហត្ថលេខាដែលស្ថិតក្រោមការដាក់ទោសទណ្ឌចំពោះការស្បថបំពាន។

13 **កាលបរិច្ឆេទនៅថ្ងៃនេះ ៖** *ខែ ថ្ងៃ ឆ្នាំ*

14 **បានចុះហត្ថលេខា ៖** *ចុះហត្ថលេខាឈ្មោះរបស់លោកអ្នកនៅទីនេះ។*

បិទភ្ជាប់នៅទីនេះ ដើម្បីបិទ។ កុំប្រើប្រដាប់កិបឬគ្រាប់កិប

ចូរពិនិត្យមើលដើម្បីឲ្យប្រាកដថា លោកអ្នកបានបំពេញរាល់ព័ត៌មានទាំងអស់បានរួចរាល់ក្នុងលិខិតថ្លែងសច្ចាអំពីការចុះឈ្មោះបោះឆ្នោតនៅផ្នែកម្ខាងទៀត!

ទម្រង់បែបបទនេះត្រូវទទួលបានដោយក្រុមប្រឹក្សានៃអ្នកកាន់បញ្ជីការ ឬគណៈកម្មការបោះឆ្នោតនៅមូលដ្ឋាន ឬបោះត្រាពីលើទម្រង់បែបបទនេះ ឬមុនកាលបរិច្ឆេទផុតកំណត់ការចុះឈ្មោះអ្នកបោះឆ្នោត (បានចុះបញ្ជីខាងក្រោម) សម្រាប់ការបោះឆ្នោត កិច្ចប្រជុំបឋម កិច្ចប្រជុំត្រៀមទុក ឬកិច្ចប្រជុំប្រចាំទីក្រុង។

ការលបរិច្ឆេទផុតកំណត់ស្រមាប់ការចុះឈ្មោះអ្នកបោះឆ្នោត

ដើម្បីចូលរួមក្នុង...	លោកអ្នកត្រូវចុះឈ្មោះ...
ការបោះឆ្នោតជុំទីមួយប្រចាំរដ្ឋ *ការបោះឆ្នោតរដ្ឋ* *ការបោះឆ្នោតជុំជម្រុះប្រចាំទីក្រុង និងទីក្រុងតូចៗ* *ការបោះឆ្នោតប្រចាំទីក្រុង និងទីក្រុងតូចៗ* *កិច្ចប្រជុំនៅទីក្រុងតូចៗតាមកម្មវិធីគ្រោងទុកជាប្រចាំ*	*យ៉ាងតិច 20 ថ្ងៃមុន*
កិច្ចប្រជុំនៅទីក្រុងតូចៗពិសេស	*យ៉ាងតិច 10 ថ្ងៃមុន*

ប្រសិនបើលោកអ្នកមិនឮព័ត៌មានពីមន្ត្រីរៀបចំការបោះឆ្នោតនៅមូលដ្ឋានរបស់លោកអ្នកក្នុងរយៈពេល 2 ឬ 3 សប្តាហ៍ សូមទូរស័ព្ទទៅមន្ត្រីទាំងនោះ!

បត់តាមខ្សែបន្ទាត់ដែលមានចំណុចដាច់ៗ។

អាសយដ្ឋានផ្ញើត្រលប់ទៅវិញ

ឈ្មោះ

លេខ និងផ្លូវ

,MA

លេខកូដស៊ីបទីក្រុង *ឬទីក្រុងតូចៗ*

បោះត្រា
ថ្នាក់ទីមួយ
នៅទីនេះ

Board of Registrars or Election Commission

City or Town Hall

MA

លេខកូដស៊ីបទីក្រុង ឬទីក្រុងតូចៗរបស់លោកអ្នក *សម្រាប់ទីក្រុង ឬទីក្រុងតូចៗ*